# ក្រមសីលធម៌ និងចរិយាមាយាទជាសកល របស់អង្គការ CHAI

# ឧបសម្ព័ន្ធ 3៖ គោលនយោបាយស្តីពីការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការការបៀតបៀនផ្លូវភេទ (PSEAH)

The Clinton Health Access Initiative, Inc. ("CHAI") មិនអត់ឱនចំពោះ រាល់គ្រប់ទម្រង់ នៃការកេងប្រវ័ញ្ច ផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ឬការបៀតបៀនខាងផ្លូវភេទទេ។ អង្គការ CHAI បានចូលរួមជាមួយសហគមន៍មិនរកប្រាក់ចំណេញអន្តរជាតិដ៏ទៃទៀត ក្នុងការគាំទ្រយ៉ាងពេញទំហឹងលើគោលការណ៍ស្នូលពាក់ព័ន្ធនឹងការទប់ស្កាត់ ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ2003 ដោយ អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ស្តីពីវិធានការពិសេសនេះ។ យើងជឿជាក់ថាមនុស្សគ្រប់រូបមានសិទ្ធិសេរីភាពរស់នៅដោយរួចផុតអំពីអំពើហិង្សាផ្លូវភេទ។

គោលការណ៍នេះអនុវត្តចំពោះបុគ្គលិក របស់អង្គការ CHAI ទាំងអស់នៅគ្រប់ពេលវេលា និងគ្រប់ទំទាក់ទំនងរបស់ពួកគេ ជាមួយអ្នកទទួលផល និងសាធារណជន។ (ក្រមសីលធម៌ និងចរិយាមាយាទជាសកលរបស់អង្គការ CHAI មានវិសាលភាពនុវត្តចំពោះ ការប្រព្រឹត្តិខុសឆ្គងខាងផ្លូវភេទ

ចំពោះបុគ្គលិកអង្គការ CHAI ឬចំពោះបុគ្គលិក នៃអង្គការជាដៃគូ ឬភ្នាក់ងាររដ្ឋាភិបាលដែលសហការជាមួយ អង្គការ CHAI, សូមមើលផ្នែកស្តីពីការបង្កើត និងថែរក្សា បរិយាកាសនៅកន្លែងធ្វើការងារ ។)

បុគ្គលិករបស់ CHAI ទាំងអស់ត្រូវតែ៖

- ប្រកាន់ខ្ជាប់នូវសីលធម៌ល្អ ក្នុងការប្រព្រឹត្តចំពោះបុគ្គលទាំងអស់ ប្រកបដោយសេចក្តីថ្លៃថ្នូរ និងការគោរព ហើយជៀសវាងឲ្យរួច អំពីការចូលរួមក្នុងសកម្មភាពនៃការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ឬការបៀតបៀនផ្លូវភេទ។
- ចូលរួមចំណែកក្នុងបរិយាកាសមួយដែលបុគ្គលិក និងអ្នកទទួលផលទាំងអស់ អាចទទួលបាននូវការទទួលស្គាល់ ចំពោះឥរិយាបថ ដែលមិនអាចទទួលយកបាន និង អាចទទួលបាននូវការពិភាក្សាស្តីអំពីសិទ្ធិ និងកង្វល់របស់ពួកគេបាន។ អ្នកគ្រប់គ្រងត្រូវមានការទទួលខុសត្រូវដាក់លាក់ក្នុងការលើកកម្ពស់បរិយាកាសនេះ។
- អាចលើកឡើងនូវកង្វល់ផ្សេងៗសមស្រប ដោយអនុលោមទៅតាមនីតិវិធី នៃការរាយការណ៍ ដែលទាក់ទងទៅនឹងករណីសង្ស័យ ថាជាការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ឬការបៀតបៀនផ្លូវភេទ។
- សហការយ៉ាងពេញទំហឹងក្នុងការស៊ើបអង្កេតរបស់អង្គការ CHAI ដោយការគោរពឯកជនភាពរបស់អ្នកដែលពាក់ព័ន្ធទាំងអស់ និង ជាពិសេសស្វ័យភាព និងសុខុមាលភាពរបស់ជនរងគ្រោះ។

## មាតិកា

I. ការទទួលខុសត្រូវ និងគោលបំណង
II. សទ្ទានុក្រម
III. បទដ្ឋាន ក្រមប្រតិបត្តិ សម្រាប់បុគ្គលិក
IV. ការអនុវត្តន៍ និងការតាមដាន
V. ការរាយការណ៍បណ្ដឹង និងក្ដីកង្វល់
VI. ការគ្មានការសងសឹក
VII. ការស៊ើបអង្កេត

# I. ការទទួលខុសត្រូវ និងគោលបំណង

ការងាររបស់អង្គការ CHAI អនុញ្ញាតឲ្យបុគ្គលិក មានទំនាក់ទំនង ជាមួយ អ្នកទទួលផល និងអ្នកដ៏ទៃផ្សេងទៀត រួមទាំងកុមារ និងប្រជាជនដែលងាយរងគ្រោះ។ តាមរយៈការងារនេះ ក៏បានធ្វើឱ្យបុគ្គលិកជាច្រើនមានជំនឿទុកចិត្ត និងមានអំណាចដែលជាពិសេសនៅពេលដែលធ្វើការចាត់ចែងធនធាន និងការបែងចែកធនធាន។

គោលបំណងនៃគោលនយោបាយនេះ គឺដើម្បីបង្កើតបរិយាកាសដ៏ល្អមួយដែលផ្ដល់ សុវត្ថិភាពសម្រាប់អ្នកទទួលផល និងសាធារណជន ហើយនឹងដើម្បីការពារកុមារ និងមនុស្សពេញវ័យដែលងាយរងគ្រោះ អំពីគ្រោះថ្នាក់ណាមួយ នៅពេលដែលមានការទាក់ទងជាមួយអង្គការ CHAI ។ វាក៏បង្កើតនូវនីតិវិធីដើម្បីដោះស្រាយឧប្បត្តិហេតុ នៃការកេងប្រវ័ញ្ច ផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ ហើយនឹងដើម្បីជូនដំណឹងដល់បុគ្គលិក អំពីការទទួលខុសត្រូវតាមផ្លូវច្បាប់ និងការទទួលខុសត្រូវខាងសីលធម៌ របស់ពួកគេ ដើម្បីការពារកុមារ និងមនុស្សពេញវ័យងាយរងគ្រោះ

នៅក្នុងគ្រប់វិស័យទាំងអស់ នៃការងាររបស់អង្គការ CHAI ។

គោលនយោបាយនេះ គឺជាផ្នែកមួយដើម្បីពង្រីកបន្ថែមទៀតនៃក្រមសីលធម៌ និងចរិយាមាយាទសកលលោករបស់អង្គការ CHAI ហើយដែលត្រូវបានអនុម័តដោយក្រុមថ្នាក់ដឹកនាំជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាលរបស់អង្គការCHAI។ នាយកជាន់ខ្ពស់ផ្នែកធនធានមនុស្សរបស់អង្គការ CHAI ដើរតួជាមន្ត្រីបង្គោលជាន់ខ្ពស់សម្រាប់ការទប់ស្កាត់ ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវ និងការបៀតបៀនផ្លូវភេទ ដែលមានការទទួលខុសត្រូវក្នុងការអនុវត្តន៍ និងការត្រួតពិនិត្យលើគោលនយោបាយនេះ ដោយមានការត្រួតពិនិត្យពីលើ អំពសំណាក់នាយកប្រតិបត្តិការរបស់អង្គការ CHAI ។

# II. សទ្ទានុក្រម

**ការចោទប្រកាន់៖** ជាបណ្តឹងជផ្លូវការទាក់ទងនឹងការរំលោភបំពានទាក់ទីននឹងក្រមសីលធម៌ និងចរិយាមាយាទជាសកលរបស់អង្គការ CHAI ដែលប្រព្រឹត្តដោយបុគ្គលិកណាម្នាក់។

**អ្នកទទួលផល**៖ បុគ្គលម្នាក់ក្រៅពីបុគ្គលិករបស់អង្គការ CHAI ដែលទទួលបានជំនួយតាមរយៈសកម្មភាពការងាររបស់អង្គការ CHAI ហើយដូច្នេះ គាត់ស្ថិតនៅក្នុងការពឹងផ្អែក ឬក្នុងបន្ទុកមួយចំនួនពីអង្គការ CHAI ។

**កុមារ**៖ ជារូបវ័នបុគ្គលណាម្នាក់ដែលមានអាយុក្រោម 18 ឆ្នាំ ដោយមិនគិតអំពីនិយមន័យក្នុងប្រទេស នោះក្នុងអំឡុងពេលដែលកុមារនោះឈានដល់ភាពពេញវ័យ។

**ដើមបណ្តឹង៖** ជាបុគ្គលដែលធ្វើបណ្តឹង រួមទាំងជនរង
គ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀន
ឬអ្នកដទៃទៀតដែលបានដឹងអំពីបទល្មើស
និងរបាយការណ៍/បញ្ជូនបន្តនូវការចោទប្រកាន់។

**ភស្តុតាង៖** ជាព័ត៌មានដែលប្រមូលបានក្នុងអំឡុងពេលដំណាក់កាល
នៃការស៊ើបអង្កេតដែលមានលក្ខណៈស្របឬផ្ទុយពីការចោទប្រកាន់។

**មន្ត្រីបង្គោល៖** ជាអ្នកដែលដែលបានតែងតាំងដោយអង្គការ CHAI
ដើម្បីទទួលខុសត្រូវលើ PSEAH រួមទាំងជាអ្នកទទួលពាក្យបណ្តឹង
អំពីករណីដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន
និងការបៀតបៀន។

**ក្រមសីលធម៌ និងចរិយាមាយាទជាសកល៖** សំណុំបទដ្ឋាន
(ឬជាស្តង់ដារ) ដែលបុគ្គលិករបស់អង្គការ CHAI
ទាំងអស់មានកាតព្វកិច្ចអនុវត្តឲ្យបានខ្ជាប់ខ្ជួន។

**អ្នកស៊ើបអង្កេត៖** ជាបុគ្គលដែលត្រូវបាន
ចាត់តាំងដោយមន្ត្រីបង្គោលជាន់ខ្ពស់ជាន់ខ្ពស់របស់អង្គការ CHAI
ឬអ្នកត្រូវគេចាត់តាំងដើម្បីស៊ើបអង្កេតលើពាក្យបណ្តឹងជាក់លាក់ណាមួ
យ។ អ្នកស៊ើបអង្កេតអាចជាសមាជិកបុគ្គលិករបស់អង្គការ CHAI
ឬអ្នកស៊ើបអង្កេតខាងក្រៅ។

**ដៃគូ៖** គឺជាំទីភ្នាក់ងារណាមួយ ឬអង្គការដែលដើរតួនាទីដ៏សំខាន់
ក្នុងការគាំទ្រដល់ការអនុវត្ត កម្មវិធីរបស់អង្គការ CHAI

មានតួនាទីក្នុងការអនុវត្តន៍ លើការសំរបសំរួល ឬអនុវត្តសកម្មភាពក្នុងនាមជាអង្គការ CHAI ។

**ការរំលោភបំពានផ្លូវភេទ**[1]៖ ការរំលោភបំពានលើរាងកាយជាក់ស្តែង ឬការគំរាមកំហែង ផ្លូវភេទណាមួយ មិនថាដោយកម្លាំង ឬក្រោមលក្ខខណ្ឌមិនស្មើភាពគ្នា ឬការបង្ខិតបង្ខំ។

**ការកេងប្រវ័ញ្ចផ្លូវភេទ** [2]៖ ជាការរំលោភបំពានជាក់ស្តែង ឬការប៉ុនប៉ងណាមួយនៅក្នុងលក្ខខណ្ឌនៃ ភាពងាយរងគ្រោះ, ដោយគ្មានអំណាចស្មើគ្នា ឬក៏គ្មានការទុកចិត្តសម្រាប់គោលបំណង ផ្លូវភេទ រួមទាំងការទាញយកផលចំនេញតាមរូបភាពជារូបិយវត្ថុ សង្គម ឬនយោបាយ ពីការកេងប្រវ័ញ្ចផ្លូវភេទនោះនៃកត្តាដ៏ទៃផ្សេងទៀត។

**ការបៀតបៀនផ្លូវភេទ**[3]៖ ការទាក់ទងសកម្មភាពផ្លូវភេទដែលមិនមានការព្រមព្រៀងជាមុន ការស្នើសុំស្នេហាផ្លូវភេទ ជាពាក្យសម្តី ឬជាការប្រព្រឹត្តជាក់ស្តែង ឬកាយវិការបង្ហាញជាសញ្ញាផ្លូវភេទ ឬឥរិយាបថផ្សេងៗទៀតដែលមានលក្ខណៈផ្លូវភេទ នៅពេលដែលការប្រព្រឹត្តបែបនេះនាំឲ្យមានការបង្អាក់ការងារ, ជាការដាក់លក្ខខណ្ឌដើមបីដោះដូរនឹងការងារណាមួយ ឬការបង្កើតបរិយាកាសគំរាមកំហែង បំភិតបំភ័យ ឬប្រមាថមើលងាយ។ ការបៀតបៀនផ្លូវភេទអាចត្រូវបានប្រព្រឹត្តដោយផ្ទាល់ ឬពីចម្ងាយដោយរួមទាំងតាមរយៈទូរស័ព្ទ អ៊ីម៉េល ឬបណ្តាញផ្សព្វផ្សាយសង្គម។ នៅពេលដែលមាន ទំរង់នៃឥរិយាបថ

---

[1] ប្រភព៖ ព្រឹត្តិបត្រអគ្គលេខាធិការអង្គការសហប្រជាជាតិ (ST/SGB/2003/13) ។
[2] ប្រភព៖ ព្រឹត្តិបត្រអគ្គលេខាធិការអង្គការសហប្រជាជាតិ (ST/SGB/2003/13) ។
[3] ប្រភព៖ ប្រែប្រួលពីព្រឹត្តិបត្ររបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ (ST/SGB/2008/5) ។

នៃការបៀតបៀនមួយបានកើតឡើង វាអាច ជាទម្រង់បែប ជាឧប្បត្តិហេតុដែលប្រព្រឹត្តដោយភាគីតែម្ខាង។ ការបៀតបៀនផ្លូវភេទ អាចកើតឡើង រវាងមនុស្សដែលមាភេទផ្ទុយគ្នា ឬមនុស្សដែលមានភេទដូចគ្នា។ គ្រប់ភេទទាំងអស់អាចជាជនរងគ្រោះ ឬជាជនល្មើស។

**ការប្រព្រឹត្តខុសឆ្គងខាងផ្លូវភេទ៖** សម្រាប់គោលបំណងនៃគោលនយោបាយនេះ វាជាច្បាប់សំរាប់អនុវត្ត លើការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន ឬការបៀតបៀនដូចដែលបានចែងខាងលើ។

**បុគ្គលិក/បុគ្គលិកសមាជិក៖** ជាបុគ្គលដែលធ្វើការងារពេញម៉ោង ឬក្រៅម៉ោងឱ្យ ឬតំណាងឱ្យអង្គការ CHAI ទោះបីជាគាត់ត្រូវបានផ្តល់សំណងជាប្រាក់សម្រាប់ការងារ ឬតំណាងក៏ដោយ។ នេះរាប់បញ្ចូលទាំងអ្នកស្ម័គ្រចិត្ត និងអ្នកជំនួសការងារក្នុងរយៈពេលជាក់លាក់មួយ។

**ជនជាប់ចោទ (ចុងចោទ) (SOC)៖** បុគ្គលដែលត្រូវគេចោទ ឬត្រូវបានគេសង្ស័យថាបានប្រព្រឹត្តការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន ឬការបៀតបៀនផ្លូវភេទដល់ជនរងគ្រោះ។

**ជនរងគ្រោះ៖** បុគ្គលដែលត្រូវបានគេកេងប្រវញ្ច័ រំលោភបំពាន ឬបៀតបៀនផ្លូវភេទ។

**សាក្សី៖** បុគ្គលទាំងឡាយណាដែលមានព័ត៍មាន ដែលអាចពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត រួមទាំងពត៍មានអំពីជនរងគ្រោះ

ដើមបណ្តឹង ជាបុគ្គលិកណាម្នាក់ នៃអង្គការដៃគូ ជាជនជាប់ចោទ ឬជាបុគ្គលិកដ៏ទៃផ្សេងទៀត។

# III. បទដ្ឋានក្រមប្រតិបត្តិ នៃបុគ្គលិក

*ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និង ការបៀតបៀនផ្លូវភេទ គឺជាបទល្មើសធ្ងន់ធ្ងរ ហើយ ការរំលោភបំពានណាមួយលើបទដ្ឋានទាំងនេះ អាចជាមូលដ្ឋានសម្រាប់ការដាក់វិន័យរហូតដល់ រហូតដល់ការបញ្ឈប់ពីការងារភ្លាមៗ។* បុគ្គលិករបស់ អង្គការ CHAI ណាម្នាក់ ដែលបានប្រព្រឹត្តអំពើកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ឬការបៀតបៀនខាងផ្លូវភេទ ក៏អាចទទួលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ឬសកម្មភាពផ្លូវច្បាប់ផ្សេងៗ ក្រោមច្បាប់ជាធរមាន ។

1. បុគ្គលិករបស់អង្គការ CHAI មិនត្រូវមានការពាក់ព័ន្ធជាដាច់ខាតនឹងអំពើកេងប្រវញ័ផ្លូវភេទ ឬទទួលប្រយោជន៍ពីអំពើកេងប្រវ័ញ្ចផ្លូវភេទពីអ្នកដទៃឡើយ។ ជាឧទាហរណ៍ ប្រសិនបើបុគ្គលិកណាម្នាក់របស់អង្គការ CHAI បានប្រើឋានៈរបស់ខ្លួន ឬអំណាចរបស់ខ្លួន ដើម្បីដោះដូរយកការរួមភេទដើម្បីបម្រើប្រយោជន៍ខ្លួននោះ ទង្វើនេះត្រូវបានចាត់ទុកជាការកេងប្រវ័ញ្ចផ្លូវភេទ។

2. បុគ្គលិករបស់អង្គការ CHAI មិនត្រូវពាក់ព័ន្ធនឹងអំពើរំលោភបំពានផ្លូវភេទជាដាច់ខាត ឬទទួលប្រយោជន៍ពីការរំលោភបំពានផ្លូវភេទពីអ្នកដទៃឡើយ។ ជាឧទាហរណ៍ ប្រសិនបើបុគ្គលិកណាម្នាក់របស់អង្គការ CHAI ប្រើកំលាំង

ឬការបង្ខិតបង្ខំ ដើម្បីសកម្មភាពផ្លូវភេទ នេះគឺជាការបំពានផ្លូវភេទ។ សកម្មភាពទាំងនោះរួមមានការថើប ឬការស្ទាបអង្អែល រហូតដល់ការរំលោភបំពានផ្លូវភេទធ្ងន់ធ្ងរ។

3. បុគ្គលិករបស់អង្គការ CHAI ត្រូវជៀសវាងដាច់ខាតនូវអំពើបៀតបៀនផ្លូវភេទ។ ជាឧទាហរណ៍ ប្រសិនបើបុគ្គលិកណាម្នាក់របស់អង្គការ CHAI ប្រើពាក្យសំដីអាសអាភាសមិនសមរម្យ ឬការបំពាបំពានលើរូបរាងកាយផ្លូវភេទ ការនិយាយរឿងកំប្លុកកំប្លែងអំពីផ្លូវភេទ ឬសរសេរទាក់ទងនឹងការរួមភេទ និង/ឬ ការនិយាយដើមអ្នកណាម្នាក់ទាក់ទងនឹងជីវិតផ្លូវភេទរបស់គេ ទាំងនេះគឺត្រូវចាត់ទុកជាការបៀតបៀនផ្លូវភេទ។

4. ហាមដាច់ខាតការរួមភេទជាមួយកុមារ (មនុស្សដែលមានអាយុក្រោម 18 ឆ្នាំ) បើទោះជា មនុស្សមួយចំនួនធំនៃក្រុមណាមួយ ឬនៅក្នុងតំបន់ណាមួយ អនុញ្ញាតឱ្យក៏ដោយ។ ច្បាប់មិនការពារទេ ចំពោះជំនឿខុសឆ្គង ដែលអនុញ្ញាតឱ្យរួមភេទជាមួយកុមារក្រោមអាយុដែលបានកំណត់ដោយច្បាប់ខាងលើ ។

5. ហាមដាច់ខាតក្នុងការឧបត្ថម្ភ ឬការបង់ជាសាច់ប្រាក់ ការផ្តល់ឲ្យនូវការងារ ការឱ្យជារបស់របរ (ទំនិញ) ឬសេវាកម្ម ផ្សេងៗ ដើម្បីដោះដូរយកសកម្មភាពនៃការរួមភេទ ដូចគ្នានេះដែរ ការឧបត្ថម្ភ ឬការចាត់ចែងផ្តល់ឱ្យបុគ្គលផ្សេងទៀត ដើម្បីដោះដូរយកការរួមភេទ បើទោះជាសកម្មភាពនោះប្រព្រឹត្តឡើងនៅក្រៅម៉ោង

ធ្វើការងារក៏ដោយ ក៏ត្រូវហាមឃាត់ជាដាច់ខាត។
នេះរួមបញ្ចូលទាំងការឧបត្ថម្ភ ឬការផ្តល់ជំនួយជូនដល់អ្នកទទួលផល
ប្រសិនបើសកម្មភាពនេះត្រូវបានគេយកមកប្រើជាមធ្យោបាយដើម្បី ដោះដូរយកការរួមភេទ សកម្មភាទាំងនោះត្រូវចាត់ទុកថាជាការបង្ខិតបង្ខំសកម្មភាពផ្លូវភេទ។

6. អង្គការ CHAI មិនលើកទឹកចិត្តសោះឡើយរាល់សកម្មភាពទាក់ទីននឹងផ្លូវភេទ រវាងបុគ្គលិករបស់អង្គការ CHAI ជាមួយនិងអ្នកទទួលផល ដែលមានការប្រស្រ័យទាក់ទង ដោយផ្ទាល់ក្នុងការផ្តល់ជំនួយដល់អ្នកទទួលផល ដោយសារតែវិសមភាពនៃអំណាចអាចធ្វើឱ្យប៉ះពាល់ដល់ ភាពជឿជាក់ និងភាពសុចរិតនៃការងាររបស់អង្គការ CHAI ។ បុគ្គលិកអាចពិគ្រោះយោបល់ជាមួយមន្ត្រីបង្គោល ដើម្បីទទួលការណែនាំអំពីភាពត្រឹមត្រូវនៃទំនាក់ទំនងជាក់លាក់ណាមួយ។ (ដើម្បីចៀសវាងនូវចម្ងល (មន្ទិល) កថាខណ្ឌនេះមិនអនុវត្តឡើយចំពោះអ្នកដែលធ្វើការឱ្យអង្គការជាដៃគូ ឬទីភ្នាក់ងាររបស់រដ្ឋាភិបាលដែល ទទួលបានជំនួយពីសកម្មភាពរបស់អង្គការ CHAI លើកលែងចំពោះតែក្នុងកម្រិតដែលពួកគេទទួល បានជំនួយផ្ទាល់ពីអង្គការ CHAI ។ ក្រមសីលធម៌ និងចរិយាមាយាទសកលរបស់អង្គការ CHAI មានវិសាលភាពក្នុងការអនុវត្តន៍រវាងបុគ្គលិកអង្គការ CHAI ជាមួយនឹងរូបវ័នបុគ្គល។)

7. នៅពេលណាដែលបុគ្គលិករបស់អង្គការ CHAI ណាម្នាក់មាន ក្ដីបារម្ភ ឬមានការសង្ស័យពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ឬការបៀតបៀនផ្លូវភេទ ពីសំណាក់មិត្តរួមការងារណាម្នាក់ មិនថានៅអង្គការ CHAI ឬនៅអង្គការដ៏ទៃផ្សេងទៀតទេ គាត់ត្រូវតែរាយការណ៍ អំពីក្ដីកង្វល់ទាំងនោះ តាមរយៈនីតិវិធី នៃការរាយការណ៍ពាក្យបណ្ដឹង ដែលមានរៀបរាប់ខាងក្រោម ឬរាយការណ៍ទៅ នាយកដ្ឋាន *លើកកម្ពស់ក្រម និងការរាយការណ៍នូវក្ដីកង្វល់* នៃក្រមសីលធម៌និងចរិយាមាយាទសកលរបស់អង្គការ CHAI។

8. បុគ្គលិករបស់អង្គការ CHAI ទាំងអស់មានកាតព្វកិច្ចបង្កើត និង ថែរក្សាបរិយាកាសការងារល្អ ដើម្បីទប់ស្កាត់រាល់ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភ បំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ។ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ត្រូវតែគាំទ្រ និងបង្កើតប្រព័ន្ធផ្សេងៗ ដើម្បីថែរក្សាបរិយាកាសការងារនេះ និងចាត់វិធានការជាបន្ទាន់ ដើម្បីឆ្លើយតបទៅនឹងក្ដីកង្វល់ដែលបានរាយការណ៍។ អ្នកគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ត្រូវតែគោរពតាមនីតិវិធីនៃការរាយការណ៍ទាក់ ទងនឹងក្ដីកង្វល់ដែលបានលើកឡើងជាមួយពួកគេ។

ចំពោះបទដ្ឋានទាក់ទងនឹងទំនាក់ទំនងរបស់បុគ្គលិកអង្គការ CHAI ជាមួយនឹងបុគ្គលិករបស់អង្គការ CHAI ដ៏ទៃផ្សេងទៀត និងទំនាក់ទំនងរបស់បុគ្គលិកអង្គការ CHAI ជាមួយនឹងបុគ្គលិកនៃអង្គការជាដៃគូ និងទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗដែលអង្គការ CHAI ធ្វើការងារជាមួយ សូមមើលក្រមសិលធម៌ និងចរិយាមាយាទសកលរបស់អង្គការ CHAI ។

# IV. ការអនុវត្តន៍ និងការតាមដាន

រាល់ការចោទប្រកាន់អំពីការប្រព្រឹត្តមិនត្រឹមត្រូវ ឬអាកប្បកិរិយាមិនសមរម្យ នឹងត្រូវគេស៊ើបអង្កេតដោយយុត្តិធម៌ និងអនុលោមតាមនីតិវិធី និងគោលនយោបាយរបស់អង្គការ CHAI ។ អង្គការ CHAI នឹងធ្វើអ្វីគ្រប់យ៉ាងដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ និងដើម្បីការពារជនរងគ្រោះ នៅពេលពួកគេមានការព្រួយបារម្ភអំពីបញ្ហាដែលបានលើកឡើង។ ដើម្បីសម្រេចបាននូវគោលបំណងនេះអង្គការ CHAI បានប្តេជ្ញាចិត្តក្នុងការចាត់វិធានការដូចខាងក្រោមៈ

- ចាត់តាំងឱ្យនាយកប្រតិបត្តិការ ជាអ្នកត្រួតពិនិត្យមើលលើនីតិវិធី នឹងគោលនយោបាយរបស់ PSEAH ឱ្យមានប្រសិទ្ធភាពខ្ពស់ រាយការណ៍អំពីវឌ្ឍនៈភាព និងបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់ក្នុងការឆ្លើយតបទៅនឹង ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ។

- ចាត់តាំងនាយកជាន់ខ្ពស់ផ្នែកធនធានមនុស្ស ជាប្រធានបង្គោលជាន់ខ្ពស់នៅអង្គការ CHAI សម្រាប់ទទួលខុសត្រូវរាល់សកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធទៅនឹង PSEAH និងជាមន្ត្រីបង្គោលទទួលខុសត្រូវ ក្នុងការចាត់តាំងជនបង្គោលដ៏ទៃផ្សេងទៀត និងចាត់តាំងអ្នកស៊ើបអង្កេត ដើម្បីធ្វើការស៊ើបអង្កេត និងធ្វើរបាយការណ៍ ជូនដល់នាយកប្រតិបត្តិការជាន់ខ្ពស់ និងក្រុមថ្នាក់ដឹកនាំកំពូល (SLT) ព្រមទាំងក្រុមប្រឹក្សាភិបាលតាមការគួរ។

- ដើម្បីអនុលោមទៅតាមច្បាប់ដែលនៅជាធរមាននិងការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់អង្គការ CHAI ដើម្បីទប់ស្កាត់ការជួលបុគ្គលិក ឬការបន្តជួលបុគ្គលិកដែលជាចារី (ជនល្មើស) ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ។ ដើម្បីសម្រេចបាននូវកិច្ចការនេះគឺអង្គការតម្រូវឲ្យមានការត្រួតពិនិត្យលើប្រវត្តិរូប និងការត្រួតពិនិត្យលើលិខិតថ្កោលទោស។
- រាល់ការស៊ើបអង្កេតទៅលើការចោទប្រកាន់ស្តីអំពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ ដែលពាក់ព័ន្ធនឹងបុគ្គលិករបស់អង្គការ CHAI ឱ្យទាន់ពេលវេលា និងប្រកបដោយវិជ្ជាជីវៈ និងដើម្បីធានានូវ ភាពត្រឹមត្រូវនៃដំណើរការឲ្យអស់ពីលទ្ធភាពរបស់ខ្លួន។ អ្នកស៊ើបអង្កេតត្រូវតែធ្វើការស៊ើបអង្កេត ដោយមិនលំអៀង ត្រូវតែគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ ដើមបណ្តឹង ជនរងគ្រោះ និងជនជាប់ចោទ។ កិច្ចការងារនេះត្រូវរួមបញ្ចូលទាំងការធ្វើបទសម្ភាសន៍ជាមួយ ដើមបណ្តឹង សាក្សី ជាពិសេសជាមួយនឹងកុមារ ត្រូវតែធ្វើឡើងដោយអ្នកស៊ើបអង្កេតអាជីព ឬអ្នកស៊ើបអង្កេតដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ដែលអាចធានាបាន។ អង្គការ CHAI នឹងចាត់វិធានការសមស្របដោយលើលទ្ធផលដែលបានរកឃើញពីការស៊ើបអង្កេត ហើយចាត់ទុកវាជាមេរៀនដែរ ដើម្បីកែលម្អគោលនយោបាយ និងបន្តអនុវត្តតាមការគួរ។
- ផ្តល់ការបណ្តុះបណ្តាល ជាទៀងទាត់លើប្រធានបទពាក់ព័ន្ធនឹង PSEAH សំរាប់បុគ្គលិកទាំងអស់របស់អង្គការ CHAI។
- ដាក់បញ្ចូលគោលនយោបាយ PSEAH

នៅក្នុងកិច្ចព្រមព្រៀងជាមួយអង្គការដៃគូរ និងកិច្ចព្រមព្រៀងបន្ត ហើយនិងតម្រូវឱ្យពួកគេរាយការណ៍មកអង្គការ CHAI ជាបន្ទាន់នូវរាល់អាកប្បកិរិយាទាំងឡាយណា ដែលគេជឿថា ជាការរំលោភបំពានលើគោលនយោបាយនេះ។

- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវគោលនយោបាយនេះ។
- ធានាឱ្យមានធនធានគ្រប់គ្រាន់ ដើម្បីផ្តល់ជំនួយសង្គ្រោះបន្ទាន់ និងការគាំទ្រផ្នែកចិត្តសាស្ត្រសមស្រប ដែលនឹងជួយដល់ជនរងគ្រោះ និងអ្នកដ៏ទៃផ្សេងទៀតដែលរងផលប៉ះពាល់ ពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ។

## V. ការរាយការណ៍ បណ្តឹង និងក្តីកង្វល់

ក្តីកង្វល់ទាំងអស់ ដែលទាក់ទងនឹងការរំលោភបំពានផ្លូវភេទជាក់ស្តែង ឬការដែលអាចកើតមាននូវការប្រព្រឹត្តខុសពាក់ព័ន្ធនឹងផ្លូវភេទ ឬការរំលោភបំពានលើគោលនយោបាយនេះ ខាត់ខាតត្រូវតែធ្វើការរាយការណ៍ជាបន្ទាន់។ អង្គការ CHAI នឹងធ្វើចំណាត់ការដើម្បីឆ្លើយតបទៅនឹងពាក្យបណ្តឹង ឬការសង្ស័យ អំពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ឬការបៀតបៀនផ្លូវភេទ បើទោះជាវាស្ថិតនៅក្នុងដំណាក់កាលនៃពាក្យចចាមអារ៉ាមក៏ដោយ។ វាមិនចាំបាច់ទាល់តែមានភស្តុតាងនោះទេ ទើបអាចធ្វើសេចក្តីរាយការណ៍ អំពីក្តីកង្វល់នៃបញ្ហានេះបាន។

ប្រសិនបើបុគ្គលណាម្នាក់មានអារម្មណ៍ថាគេមិនអាចទទួលបាននូវអ្វីដែលគេបានជួបឬក៏ឮ ដែលអាចជាការរំលោភបំពានលើគោលនយោបាយនេះ គឺជាបុព្វហេតុដែលយើងអាចដាក់ពាក្យបណ្ដឹងបាន។

អ្នកប្ដឹងត្រូវតែមានអារម្មណ៍ថាពួកគេមានសុវត្ថិភាពក្នុងការរាយការណ៍ ក្ដីកង្វល់របស់ពួកគេត្រូវបានគេស្ដាប់ និងមានចំណាត់ការទាន់ពេលវេលា។ អង្គការ CHAI ប្ដេជ្ញាចិត្តខ្ពស់ក្នុងការលើកទឹកចិត្តឱ្យបុគ្គលិក និងអ្នកទទួលផលទាំងអស់ហ៊ានចេញមុខ និងលើកឡើងនូវកង្វល់ទាំងឡាយដែលពួកគេជាធម្មតាឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន ដើម្បីឱ្យកង្វល់ទាំងនេះត្រូវបានដោះស្រាយទាន់ពេលវេលា។ បុគ្គលិកនិងអ្នកទទួលផល គួរទទួលបានអារម្មណ៍ទុកចិត្ត និងកក់ក្ដៅក្នុងការរាយការណ៍ អំពីបទល្មើសណាមួយ ដែលទាក់ទិននឹងការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងការបៀតបៀនផ្លូវភេទ - សម្រាប់ករណីទាំងពី អតីតកាល ឬបច្ចុប្បន្នកាល។

អង្គការ CHAI នឹងចាត់វិធានយ៉ាងម៉ត់ចត់ ប្រកដោការយកចិត្តទុកដាក់ខ្ពស់ ក្នុងចំណាត់ការចំពោះរាល់ក្ដីកង្វល់ទាំងអស់។ បុគ្គលិកអាចរាយការណ៍អំពីបញ្ហាណាមួយដោយអនាមិក ប្រសិនបើពួកគេមិនចង់ចេញមុខដោយផ្ទាល់។

ពាក្យបណ្ដឹង និងក្ដីកង្វល់ អាចត្រូវបានដាក់ជូនតាមវិធីមួយ ឬច្រើនដូចខាងក្រោមនេះ៖

- **បុគ្គលិករបស់អង្គការ CHAI អាចទាក់ទងរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់គាត់។**

- **រាយការណ៍ទៅកាន់មន្ត្រីបង្គោលជាន់ខ្ពស់របស់អង្គការ CHAI ឬមន្ត្រីបង្គោលដ៏ទៃផ្សេងទៀត ដែលអង្គការ CHAI បានចាត់តាំងដោយ។**

- **ទាក់ទងមកកាន់បណ្តាញផ្តល់ជំនួយរបស់អង្គការ CHAI។** បណ្តាញផ្តល់ជំនួយ គឺជាសេវាកម្ម "ជាអ្នកប្រកាសអាសន្នផ្តល់ដំណឹង" របស់ភាគីទីបីដែលអនុញ្ញាតឱ្យបុគ្គលណាម្នាក់ៗរាយការណ៍ (ជាអនាមិក ឬជម្រាបឈ្មោះ) ចំពោះករណីដែលអាចកើតមាននៃការប្រព្រឹត្តមិនត្រឹមត្រូវ។ សេចក្តីរាយការណ៍អនាមិកនឹងត្រូវបានយកចិត្តទុកដាក់ដោយម៉ឺងមាត់ដូចគ្នានឹងការរាយការណ៍ ដែលបុគ្គលម្នាក់ៗធ្វើការរាយការណ៍ដោយបង្ហាញឱ្យគេស្គាល់នូវអត្តសញ្ញាណខ្លួនឯង។

បុគ្គលិករបស់អង្គការ CHAI ទាំងអស់ត្រូវមានទំនួលខុសត្រូវក្នុងការរាយការណ៍ករណីសង្ស័យថាមានការកេងប្រវ័ញ្ចការផ្លូវភេទ ការរំលោភបំពានផ្លូវភេទ ឬការបៀតបៀនផ្លូវភេទ ដោយបុគ្គលិករបស់អង្គការ CHAI ឬអង្គការជាដៃគូ។

អ្នកដែលមានចេតនាអាក្រក់ធ្វើរបាយការណ៍ប្រឌិត (ឧទាហរណ៍ក្លែងបន្លំក្តីកង្វល់) នឹងត្រូវទទួលរងការពិន័យសមស្របទៅតាមច្បាប់ជាធរមាន ដែលបានចែង។

## VI. ការគ្មានការសងសឹក

អង្គការ CHAI នឹងមិនអត់អោនដាច់ខាតចំពោះរាល់ទម្រង់នៃការបៀតបៀន ការសងសឹក ការធ្វើឱ្យអ្នកដ៏ទៃរងគ្រោះ ឬបង្កផលវិបាកនៅកន្លែងធ្វើការងារប្រឆាំងតបនឹងបុគ្គលិកណាម្នាក់របស់អង្គការ CHAI ដែលបានរាយការណ៍នូវក្តីកង្វល់

ឬដាក់ពាក្យបណ្ដឹងដោយត្រឹមត្រូវ ស្របតាមគោលនយោបាយ
នៃក្រមសិលធម៌និងចរិយាមាយាទសកលនេះ។
បើទោះជាក្ដីកង្វល់នោះវាមានកំហុសខ្លះៗក៏ដោយ
ឱ្យតែវាប្រកបដោយសុចរិតភាព។។ បុគ្គលិករបស់អង្គការCHAI
ដែលរំលោភបំពាន សងសឹកជនរងគ្រោះ ឬធ្វើសកម្មភាពអវិជ្ជមាន
ប្រឆាំងតបនឹងជនដែលបានលើកឡើងពីក្ដីកង្វល់ដោយស្មោះត្រង់
នឹងត្រូវទទួលរងការដាក់ទោសតាមច្បាប់ជាធរមាន
និងរហូតដល់ការបណ្ដេញចេញពីការងារ។

## VII. ការស៊ើបអង្កេត

រាល់ការខិតខំប្រឹងប្រែងទាំងអស់នឹងត្រូវបានធ្វើឡើង ដើម្បី
ការពារឯកជនភាពរបស់អ្នកប្ដឹង អ្នករាយការណ៍ និងជនជាប់
ចោទទាំងអស់។ ខណៈពេលដែលអង្គការ CHAI
មិនអាចធានានូវភាពសម្ងាត់ពេញលេញបាន
ព័ត៌មានអំពីការដាក់ពាក្យបណ្ដឹង និងការស៊ើបអង្កេតត្រូវបានកំណត់
ចំពោះអ្នកដែលត្រូវការអនុញ្ញាតឱ្យដឹងអំពីបណ្ដឹងនេះ។
នៅពេលដែលជនជាប់ចោទគឺជាថ្នាក់ដឹកនាំជាន់ខ្ពស់ ជាមន្ត្រីបង្គោល
ឬជាបុគ្គលិកផ្នែកធនធានមនុស្សសកល នៅពេលនោះអ្នកទទួល
ពាក្យបណ្ដឹងត្រូវតែចាត់ការតាមនីតិវិធី
ជៀសវាងកុំឱ្យមានការពាក់ព័ន្ធជាមួយជនជាប់ចោតឱ្យសោះ
ដែលនាំឱ្យមានទំនាស់ផលប្រយោជន៍។

ក្នុងអំឡុងពេល និងបន្ទាប់ពីការស៊ើបអង្កេត បុគ្គល
ដែលដឹងអំពីសំណុំរឿង រាយការណ៍
ឬបណ្ដឹងគឺត្រូវតែគោរពជាដាច់ខាត នូវភាពសម្ងាត់នៃបញ្ហានេះ
និងតម្រូវឱ្យការការពារអត្តសញ្ញាណភាពជាឯកជន
និងកេរ្តិ៍ឈ្មោះរបស់ជនជាប់ចោទ ដើមបណ្ដឹង អ្នករាយការណ៍

ជនរងគ្រោះ និងសាក្សី។ បុគ្គលណា ដែលមិនសហការក្នុងការស៊ើបអង្កេត ឬអ្នកដែលរំលោភបំពានបំបែកការសម្ងាត់ នឹងត្រូវទទួលរងការដាក់ទណ្ឌកម្ម តាមច្បាប់ដែលបានចែងជាធរមានផងដែរ។

មន្ត្រីបង្គោលរបស់អង្គការ CHAI និងអ្នកស៊ើបអង្កេត ត្រូវចាត់វិធានការសមស្របដើម្បីការពារដើមបណ្តឹង ជនរងគ្រោះ ជនដែលរងការចោទប្រកាន់ពីបណ្តឹង អ្នករាយការណ៍ និងសាក្សពីការសងសឹក និងដើម្បីរក្សាសុវត្ថិភាពរបស់ពួកគេនៅក្នុងដំណើរការស៊ើបអង្កេត។